# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

-សាលក្រមព្រហ្មទណ្ឌលេខ ១២...ដ "ក្រ"
ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០២២
-សំណុំរឿងព្រហ្មទណ្ឌលេខ ៤៤៣
ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០២១
-សំណុំរឿងស៊ើបសួរលេខ ៣៣៥
ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០២១
-សំណុំរឿងជំនុំជម្រះលេខ ៣៥០៩
ចុះថ្ងៃទី០១ ខែតុលា ឆ្នាំ២០២១

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងរាជធានីភ្នំពេញ

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២១ វេលាម៉ោង ០៩ : ០០ នាទី នៅសាលសវនាការទី២ ជាន់ទី១ ដោយមានសមាសភាព៖

### ក្រុមប្រឹក្សាជំនុំជម្រះ

លោកអនុប្រធាន [redacted] ប្រធានក្រុមប្រឹក្សាជំនុំជម្រះ
លោក ចៅក្រមប្រឹក្សា
លោកស្រី ចៅក្រមប្រឹក្សា

### តំណាងអយ្យការ

លោក [redacted] ព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ

### ក្រឡាបញ្ជីសវនាការ

លោក [redacted] ក្រឡាបញ្ជីនៃសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ៤៤៣ ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០២១ ដែលមានជនជាប់ចោទ ៖

១/.ឈ្មោះ [redacted] XIAOFEI ភេទប្រុស កើតថ្ងៃទី១១ ខែមករា ឆ្នាំ១៩៧១ ជនជាតិចិន កាន់លិខិតឆ្លងដែនសញ្ជាតិចិនលេខ [redacted] ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៥ មុខរបរធ្វើចំការ ទីកន្លែងកំណើតខេត្តជីជាំង ប្រទេសចិន ទីលំនៅមុនពេលឃាត់ខ្លួនផ្ទ [redacted] រាជធានីភ្នំពេញ ប្រពន្ធឈ្មោះ [redacted] ដាណេ មានកូន០៣នាក់ ឪពុកឈ្មោះ [redacted] ZHICAI “ស្លាប់” ម្តាយឈ្មោះ [redacted] AYING “ស្លាប់” ទោសពីមុនគ្មាន ជានីតិជន។

- **ឃុំខ្លួនតាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៧២៤ “ប” ដ.ឃ.ដ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០២១**

មានលោក [redacted] ជាមេធាវីការពារសិទ្ធិ ។

២/.ឈ្មោះ [redacted] WEIJUN ភេទប្រុស កើតថ្ងៃទី០៦ ខែមេសា ឆ្នាំ១៩៨៥ ជនជាតិចិន កាន់លិខិតឆ្លងដែនសញ្ជាតិចិនលេខ [redacted] ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៩ មុខរបរដូរលុយ ទីកន្លែងកំណើតខេត្តក្វាងតុង ប្រទេសចិន ទីលំនៅមុនពេលឃាត់ខ្លួនខុនដូរអិលបឹងត្របែក២ អគារលេខ [redacted] រាជធានីភ្នំពេញ ប្រពន្ធឈ្មោះ [redacted] MEIFANG មានកូន០១នាក់ ឪពុក



Scanned with CamScanner

ឈ្មោះ [redacted] HUAWANG "រស់" ម្ដាយឈ្មោះ [redacted] JIUAI "រស់" ទោសពីមុនគ្មាន ជាតិចិន។

- **ឃុំខ្លួនតាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៧២៥ "ប" ដ.ឃ.ដ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០២១**

មានលោក [redacted] ជាមេធាវីការពារសិទ្ធិ ។

ជាប់ចោទពីបទ៖ **រក្សាទុក, ដឹកជញ្ជូន និងជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចគល់ស្ពានហង្ស ផ្លូវបេតុង ក្រុមទី៧៨ ភូមិ១៤ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី២០ ខែមករា ឆ្នាំ២០២១ តាមបញ្ញត្តិមាត្រា ៤៨ កថាខណ្ឌទី១, ទី២, ទី៣ និងទី៦ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន។

## **អង្គហេតុនៃរឿងមានដូចតទៅ**

កាលពីថ្ងៃទី២០ ខែមករា ឆ្នាំ២០២១ វេលាម៉ោង២១ និង៣០នាទី កម្លាំងសមត្ថកិច្ច នៃអធិការដ្ឋាននគរបាលខណ្ឌចំការមន បានដាក់គោលដៅត្រួតពិនិត្យរឹតបន្តឹងច្បាប់ចរាចរណ៍ផ្លូវគោក ត្រង់ចំណុចគល់ស្ពានហង្ស ផ្លូវបេតុង ក្រុម៧៨ ភូមិ១៤ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ក៏បានប្រទះឃើញរថយន្តមួយគ្រឿងម៉ាក MAZADA BT50 ពណ៌ស ពាក់ស្លាកលេខ ភ្នំពេញ 2AW-1997 បើកបរដោយជនត្រូវចោទឈ្មោះ [redacted] XIAOFEI និងជនត្រូវចោទឈ្មោះ [redacted] WEIJUN ជាអ្នកជិះជាមួយ។ ដោយមានការសង្ស័យក៏បានហៅឈប់ធ្វើការត្រួតពិនិត្យ ក្រោយមកក៏ឆែកឆេររកឃើញក្រាមពណ៌សថ្លាសង្ស័យជាសារធាតុញៀននៅក្នុងកាបូបខាងស្ដាំដែលជនត្រូវចោទឈ្មោះ [redacted] WEIJUN អង្គុយ។ បន្ទាប់មកក៏បានធ្វើការនាំខ្លួនមកកាន់អធិការដ្ឋាននគរបាលខណ្ឌចំការមន ដើម្បីធ្វើការសាកសួរ។ សមត្ថកិច្ចបានធ្វើការឃាត់ខ្លួនជនត្រូវចោទទាំងពីររួចដកហូតវត្ថុតាង និងកសាងសំណុំរឿងបញ្ជូនមកអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ដើម្បីចាត់ការតាមនីតិវិធីច្បាប់។

- **បានឃើញ** របាយការណ៍សំយោគលេខ ០០៤/២១ រ.ប.ក ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០២១ របស់អធិការដ្ឋាននគរបាលខណ្ឌចំការមន។

- **បានឃើញ** ដីកាសន្និដ្ឋានស្ថាពរលេខ ៣៣៩៦ អ.យ.ទ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២១ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

- **បានឃើញ** ដីកាសម្រេចបញ្ជូនរឿងទៅជំនុំជម្រះលេខ ៤៦០០ "ប" ដ.ដ ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ។

## **នាពេលសវនាការ**

- ជនជាប់ចោទឈ្មោះ [redacted] XIAOFEI បានឆ្លើយនាពេលសវនាការថា៖ ខ្លួនសូមបដិសេធចំពោះការចោទប្រកាន់នេះព្រោះថ្នាំញៀនគឺពុំមែនជារបស់ខ្លួននោះទេ។ នៅថ្ងៃកើតហេតុនោះគឺខ្លួនបានជិះឡានទៅជួប [redacted] WEIJUN នៅកន្លែងស្នាក់នៅរបស់គាត់ ដើម្បីទៅយកដុំដែកអាល់ទែ ព្រោះគាត់ត្រូវទៅស្រុកចិននៅថ្ងៃស្អែកគាត់មិនប្រើទៀតទេក៏អោយខ្លួន។ ឈ្មោះ [redacted] WEIJUN បានយកដុំដែកមកដាក់នៅឃ្លុបឡានខាងក្រោយ ហើយគាត់ឡើងជិះឡានអង្គុយខាងមុខជាមួយនឹងខ្លួនហើយ [redacted] WEIJUN បានប្រាប់ខ្លួនឱ្យជួយជូនគាត់ទៅកោះពេជ្រផង ដើម្បីលាមិត្តភក្តិរបស់គាត់ ព្រោះគាត់ត្រូវត្រឡប់ទៅប្រទេសចិនវិញនៅថ្ងៃស្អែក។ ពេលជិះឡានចេញពីផ្ទះរបស់ឈ្មោះ [redacted] WEIJUN វំលងបានពីរផ្លូវ ឈ្មោះ [redacted] WEIJUN បានឱ្យខ្លួនឈប់ឡាន ហើយ [redacted] WEIJUN បានចុះពីឡានប្រហែល២ទៅ៣នាទីក៏ត្រឡប់មកវិញ ពេលនោះ



Scanned with CamScanner

ខ្លួនមិនបានចាប់អារម្មណ៍ថាគាត់បានកាន់អ្វីមកជាមួយឬអត់នោះទេ ព្រោះខ្លួនជាប់និយាយទូរសព្ទ័ រួចក៏បន្តដំណើរទៅកោះពេជ្របន្តទៀតរហូតដល់ ចំណុចស្ពានហង្សក៏បានជួបនឹងសមត្ថកិច្ចហៅត្រួតពិនិត្យជាតិអាកុល។ ពេលនោះ [redacted] WEIJUN ស្រាប់តែមានសភាពស្លន់ស្លោរ ហើយខ្លួនក៏ឆ្ងល់ហើយសួរគាត់ថា "*មានរឿងអ្វី? កើតអីបានជាភ័យ ខ្ញុំមានបណ្ណ័បើកបរត្រឹមត្រូវមិនអីទេ ហើយក៏មិនបានផឹកស្រវឹងដែរ*" ។ ពេលនោះឈ្មោះ [redacted] WEIJUN មិនបានឆ្លើយតបមកខ្លួនវិញទេ គិតតែនិយាយថា "*ងាប់ហើយៗ*" និងបានស្រវេស្រវារកអីវ៉ាន់របស់គាត់មកទុកនៅឃ្លុបឡានខាងមុខដែលគាត់អង្គុយ។ ខ្លួនមិនបានចាប់អារម្មណ៍ថាជាអីវ៉ាន់អ្វីនោះទេ ហើយយកចូលមកពីពេលណានោះទេ ។ ពេលនោះខ្លួនក៏មិនចាប់អារម្មណ៍ហើយចុះពីឡានតាមការប្រាប់របស់សមត្ថកិច្ច ដើម្បីអោយសមត្ថកិច្ចធ្វើការត្រួតពិនិត្យ។ បន្ទាប់ពីបានឆែកឆេររួចស្រាប់តែរកឃើញថង់ខ្មៅមួយនៅឃ្លុបឡានខាងមុខ កន្លែងដែល [redacted] WEIJUN បានយកអីវ៉ាន់គាត់ដាក់ក្នុងនោះ។ បន្ទាប់មកទៀតសមត្ថកិច្ចបានទៅឆែកផ្ទះរបស់ខ្លួនបន្ត តែរកពុំឃើញមានភស្តុតាងអ្វីពាក់ពន្ធ័នឹងគ្រឿងញៀននោះទេ។ គ្រឿងញៀនក្នុងថង់ខ្មៅ នោះគឺពិតជាមិនមែនរបស់ខ្លួននោះទេ។ ខ្លួនមក កម្ពុជាច្រើនឆ្នាំមកហើយរកស៊ីត្រឹមត្រូវមិនដែលបានធ្វើអ្វីល្មើសច្បាប់ស្រុកខ្មែរនោះទេ គឺខ្លួនមានប្រវត្តល្អ ជាអាជីវករត្រឹមត្រូវ ។ ពេលសមត្ថកិច្ចឃាត់រថយន្តនោះខ្លួនមិនបានភិតភ័យអ្វីនោះទេ ព្រោះខ្លួនមិនដឹងថាត្រូវភ័យរឿងអីនោះទេ ព្រោះខ្លួនមិនបានផឹក ហើយបើកបរក៏មាន ប័ណ្ណបើកបរត្រឹមត្រូវ ។

- ជនជាប់ចោទឈ្មោះ [redacted] WEIJUN បានឆ្លើយនាពេលសវនាការថា៖ ខ្លួនសុំបដិសេធចំពោះការចោទប្រកាន់នេះ ខ្លួនមកប្រទេសកម្ពុជារយៈពេលជាងមួយឆ្នាំមកហើយ គឺមកធ្វើការនៅភោជនីយដ្ឋាន , ដូរប្រាក់ និងលក់ម្ហូបអាហារ ។ កាលពីថ្ងៃទី២០ ខែមករា ឆ្នាំ២០២១ វេលាម៉ោងជាង០៧យប់ ឈ្មោះ [redacted] XIAOFEI បានបើកឡានមកដល់ផ្ទះខ្លួន ដើម្បីមកយកដុំដែកអាល់ទែ ដែលខ្លួនអោយគាត់ព្រោះខ្លួនត្រូវទៅចិនវិញឈប់ប្រើទៀតហើយ។ ពេលគាត់មកដល់ខ្ញុំបានលើកដុំដែក ជាមួយសន្តិសុខ និងមានស្រោមដៃភ្ជាប់ជាមួយនៅដុំដែកនោះ ទៅដាក់នៅឃ្លុបឡានខាងក្រោយរបស់ឈ្មោះ [redacted] XIAOFEI។ ពេលលើកដុំដែកដាក់លើឡានរួចហើយ ខ្លួនបានឡើងជិះឡានជាមួយឈ្មោះ [redacted] XIAOFEI ។ ខ្លួនបានពឹងអោយគាត់ជួយជូនទៅកោះពេជ្រដើម្បីទៅជួបមិត្តភក្តិរបស់ខ្លួន។ ខ្លួនឱ្យឈ្មោះ [redacted] XIAOFEI បើកឡានទៅជួបមិត្តភក្តិខ្លួននៅកោះពេជ្រដើម្បីលាមិត្តភក្តិរបស់ខ្លួន ព្រោះស្អែកខ្លួនត្រូវទៅប្រទេសចិនវិញហើយ។ ពេលបើកឡានមកដល់ស្ពានហង្សកោះពេជ្រសមត្ថកិច្ចបានហៅឡានឱ្យឈប់ និងឱ្យខ្លួនចុះពីឡាន។ ពេលនោះខ្លួនមិនបានភិតភ័យអ្វីនោះទេ គឺធម្មតា។ បន្ទាប់មកសមត្ថកិច្ចបានធ្វើការឆែកឆេរឡានរកឃើញគ្រឿងញៀនពីរកន្លែងគឺរកឃើញនៅក្នុងឃ្លុបឡានខាងមុខកន្លែងខ្លួនអង្គុយ និងនៅក្នុងកាបូបនៅខាងក្រោយមួយកន្លែង។ ចំពោះគ្រឿងញៀនដែលសមត្ថកិច្ចរកឃើញនោះគឺមិនមែនជារបស់ខ្លួនទេ ហើយខ្លួនក៏មិនច្បាស់ថាថ្នាំញៀននោះជារបស់អ្នកណាដែរ។ ខ្លួនធ្លាប់ប្រើប្រាស់គ្រឿងញៀនរយៈពេលប្រហែល៣ឆ្នាំមកហើយ ប៉ុន្តែខ្លួនពុំដែលលក់ដូរគ្រឿងញៀនទេ។ សមត្ថកិច្ចបានទៅឆែកផ្ទះរបស់ ខ្លួនហើយរកឃើញឧបរណ៍ប្រើគ្រឿងញៀនមួយចំនួន។ ពេលលីដុំដែកអាល់ទែនោះខ្លួនបានពឹងអោយសន្តិសុខនោះជួយផងដែរ។. វត្ថុខ្មៅដែលតុលាការបង្ហាញក្នុងរូបភាពនេះ គឺជាស្រោមដៃដែលខ្លួនចងភ្ជាប់នឹងអាល់ទែ មិនមែនជាថង់ខ្មៅនោះទេ គឺជាស្រោមដៃ។

-សាក្សី លោកអនុសេនីយ៍ឯក [redacted] ជាមន្ត្រីនគរបាលយុត្តិធម៌ បានឆ្លើយនាពេលសវនាការថា៖ ចំពោះរូបនៅក្នុងវីដេអូនេះគឺពិតជារូបរបស់ឈ្មោះ [redacted] WEIJUN ពិតមែន។ នៅក្នុងវីដេអូនេះសមត្ថកិច្ចយើងខ្ញុំសម្គាល់ឃើញមានកញ្ចប់ថង់ខ្មៅមួយជាប់ពីក្រោយដុំដែកអាល់ទែរដែលឈ្មោះ [redacted] WEIJUN លីទៅដាក់ពីក្រោយគូទរថយន្ត ។ ជាធម្មតា *៣៧*



Scanned with CamScanner

រាល់ពេលដែលសមត្ថកិច្ចយើងខ្ញុំឃាត់ខ្លួនជនជាតិចិនដែលពាក់ព័ន្ធក្នុងករណីគ្រឿងញៀន ម្តងៗគឺជនជាតិចិនទាំងនោះបានព្យាយាមរត់គេចខ្លួនទាំងអស់។ ប៉ុន្តែនៅពេលដែលសមត្ថកិច្ចយើងខ្ញុំធ្វើការឃាត់ខ្លួនឈ្មោះ [redacted] XIAOFEI នេះគឺគាត់មិនមានការភ័យស្លន់ស្លោនោះទេ គឺមានសភាពធម្មតា ពេលដែលឃើញបារ៉ាស់របស់សមត្ថកិច្ច គាត់បើកឡានចូលជាធម្មតា ដោយមិនមានការភិតភ័យអ្វីទាំងអស់ ហើយថែមទាំងចូលរួម និងសហការយ៉ាងល្អគ្រប់នីតិវិធីជាមួយសមត្ថកិច្ចយើង។ ដោយឡែកចំពោះឈ្មោះ [redacted] WEIJUN វិញ គឺមានសភាពភ័យស្លន់ស្លោរពេលជួបនឹងសមត្ថកិច្ច ឆ្លើយក្រឡេចក្រឡុច ម្តងឆ្លើយបែបនេះ ម្តងឆ្លើយបែបនោះ ពេលសមត្ថកិច្ចសាកសួរគាត់ ហើយមិនសូវសហការ និងមិនព្រមផ្តិតមេដៃលើ ឯកសារទេ។ នៅថ្ងៃកើតហេតុខាងសមត្ថកិច្ចយើងខ្ញុំពុំបានរកឃើញ ស្រោមដៃសម្រាប់ហាត់កីឡាដូចការអះអាងរបស់ [redacted]WEIJUN នោះទេ គឺមានតែដុំដែកតែប៉ុណ្ណោះ ។ ខាងសមត្ថកិច្ចក៏បានទៅឆែកឆេរផ្ទះរបស់ឈ្មោះ [redacted] WEIJUN បានរកឃើញឧបករណ៍ប្រើប្រាស់គ្រឿនមួយចំនួន។ចំណែកផ្ទះរបស់ [redacted] XIAOFEI ពុំឃើញមានភស្តុតាងអ្វីដែលអាចពាក់ពន្ធ័គ្រឿងញៀននោះទេ។ គ្រឿងញៀននោះគឺបានរកឃើញឃ្លុបខាងមុខដែល [redacted] WEIJUN អង្គុយ ។

-សាក្សី លោកអនុសេនីយ៍ឯក [redacted] **ម៉ារ៉ា** ជាមន្ត្រីនគរបាលយុត្តិធម៌ បានឆ្លើយនាពេលសវនាការថា៖ ខ្លួនសូមបញ្ជាក់ប្រាប់សវនាការថា នាពេលនោះអត្តចរិករបស់ជនត្រូវចោទទាំងពីរនាក់នៅពេលជួបសមត្ថកិច្ចលើកដំបូង និងក្រោយពេលដែលសមត្ថកិច្ចឃាត់ខ្លួនគឺ ឃើញថាឈ្មោះ [redacted] XIAOFEI មិនភ័យស្លន់ស្លោទេ ពេលដែលឃើញប៉ារ៉ាស់របស់សមត្ថកិច្ច គាត់បើកឡានចូលជាធម្មតា ដោយមិនមានការភិតភ័យអ្វីទាំងអស់ ហើយថែមទាំងចូលរួម និងសហការយ៉ាងល្អ គ្រប់នីតិវិធីជាមួយសមត្ថកិច្ចយើង។ ចំណែកឈ្មោះ [redacted] WEIJUN វិញ គឺមានសភាពភ័យស្លន់ស្លោរពេលជួបនឹងសមត្ថកិច្ច ក្រឡេចក្រឡុច ម្តងឆ្លើយបែបនេះ ម្តងឆ្លើយបែបនោះ មិនសូវសហការ និងមិនព្រមផ្តិតមេដៃលើ ឯកសារទេ។ ចំពោះរូបនៅក្នុងវីដេអូនេះគឺពិតជារូបរបស់ឈ្មោះ [redacted] WEIJUN ពិតមែន។ នៅក្នុងវីដេអូនេះសមត្ថកិច្ចយើងខ្ញុំសម្គាល់ឃើញមានកញ្ចប់ថង់មួយជាប់ពីក្រោយដុំដែកអាល់ទែរ ដែលឈ្មោះ [redacted] WEIJUN លីទៅដាក់ពីក្រោយគូទរថយន្ត ។ **កញ្ចប់ថ្នាំញៀនគឺដកហូតចេញពីក្នុងរថយន្ត ដកចេញពីក្នុងឃ្លុបមុខខាងស្តាំរបស់រថយន្ត ដែលនៅទល់មុខកន្លែងឈ្មោះ [redacted]WEIJUN អង្គុយ ហើយវាមានទំហំ និងរូបរាងប្រហាក់ប្រហែល ទៅនឹងកញ្ចប់ដែលជាប់ទៅនឹងដុំដែកអាល់ទែររបស់ឈ្មោះ [redacted]WEIJUN ដូចមាននៅក្នុងវីដេអូនេះអញ្ចឹង។** នៅថ្ងៃកើតហេតុខាងសមត្ថកិច្ចយើងខ្ញុំពុំបានរកឃើញមានស្រោមដៃសម្រាប់ហាត់កីឡានោះទេ គឺមានតែដុំដែកតែប៉ុណ្ណោះ ក្រៅពីនេះពុំមានអ្វីទៀតទេ។

-សាក្សី លោក [redacted] **រដ្ឋា** ជានាយផ្នែកអន្តរាគមន៍ បានឆ្លើយនាពេលសវនាការថា៖ ខ្លួនជាអ្នកចុះប្រតិបត្តិការផ្ទាល់ នៅថ្ងៃកើតហេតុសមត្ថកិច្ចយើងបានដាក់គោលដៅត្រួតពិនិត្យរឹតបន្តឹងច្បាប់ចរាចរណ៍ត្រង់ចំណុចគល់ស្ពានហង្សផ្លូវបេតុង ក្រុម៧៨ ភូមិ១៤ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ពេលនោះមានរថយន្តមួយគ្រឿងម៉ាក MAZADA BT50 ពណ៌ស ពាក់ស្លាកលេខ ភ្នំពេញ 2AW-1997 ដែលសមត្ថកិច្ចយើងបានហៅអោយឈប់ដើម្បីធ្វើការឆែកឆេរ ស្រាប់តែពេលឈ្មោះ TU WEIJUN ចុះពីលើឡានមានសភាពភ័យញ័រញ៉ូវខ្លួន ខ្លួនក៏បានអោយកងកម្លាំងគ្រប់គ្រងគាត់សិន បន្ទាប់មកឆែកឆេរក្នុងឡាន។ ចំណែកឈ្មោះ [redacted] XIAOFEI មានសភាពធម្មតា នឹងនរ មិនមានការភិតភ័យទេ។ ពេលដែលឃើញប៉ុស្តិ៍ត្រួតពិនិត្យឈ្មោះ [redacted]XIAOFEI បានបើករថយន្តចូលឱ្យសមត្ថកិច្ចធ្វើការត្រួតពិនិត្យធម្មតា មិនមានការគេចវេសនោះទេ ហើយនៅក្រោយពេលឆែកឆេរអាការៈរបស់ឈ្មោះ [redacted]XIAOFEI មានសភាពធម្មតា មិនមានការភិតភ័យទេ ព្រមទាំងបានចូលរួមសហការណ៍ជាមួយសមត្ថកិច្ចទៀតផង។ វត្ថុតាងដែលជាកញ្ចប់ថ្នាំញៀន គឺនៅ

ក្នុងថង់ខ្មៅតែមួយថង់នោះទេ ដោយដកហូតចេញពីក្នុងរថយន្ត នៅក្នុងឃ្លុបមុខខាងស្តាំរបស់រថយន្ត ដែលនៅទល់មុខកន្លែងឈ្មោះ [redacted] WEIJUN អង្គុយ។ ចំណែកនៅក្នុងកាប៊ូបខាងក្រោយគ្មានថ្នាំញៀនដូចការអះអាងរបស់ [redacted] WEIJUN នោះទេ គ្រឿងញៀនរកឃើញតែនៅក្នុងឃ្លុបខាងមុខនោះមួយកន្លែងគត់។ ពេលឆែកឆេរ ដុំដែកនៅក្នុងឃ្លុបឡានមិនមានស្រោមដៃនោះទេ។ ជាធម្មតាពេលចាប់ថ្នាំញៀន ពួកដែលគាត់ជួញដូរ និងប្រើប្រាស់ថ្នាំញៀន តែងតែមានសភាពភ័យគ្រប់គ្នា តែឃើញ [redacted] XIAOFEI មិនភ័យអ្វីនោះទេ។

-ក្រឡាបញ្ជីអានចម្លើយរបស់សាក្សីឈ្មោះ [redacted] **ចន្ថា** ជាសន្តិសុខការពារនៅកន្លែងស្នាក់នៅរបស់ [redacted] WEIJUN ដែលបានឆ្លើយថា៖ រូបភាពដែលនៅក្នុងវីឌីអូនោះជារូបខ្លួនជាមួយជនជាតិចិន ប្រាកដមែន។ នៅយប់កើតហេតុជនជាតិចិនលើកដែកអាល់ទែចំនួនពីរគឺធំមួយតូចមួយ។ ដែកអាល់ទែរធំ ពេលខ្លួនឃើញ គាត់លីអាល់ទែរខ្លួនទៅរកជួយលើកដាក់គូទឡាន តែគាត់ពុំឱ្យខ្លួនប៉ះនោះទេ ដោយគាត់បាននិយាយថា មិនបាច់ ជួយទេ។ រាល់ពេលគាត់ចេញចូលកន្លែងមកគាត់ពុំដែលពាក់ម៉ាស់ទេ តែនៅយប់កើតហេតុនោះគាត់ពាក់ម៉ាស់ ហើយមានសភាពដើរប្រញាប់ៗ។ ចំពោះវត្ថុពណ៌ខ្មៅថង់ភ្ជាប់នៅនឹងដុំដែកអាល់ទែ ខ្លួនពុំបានចាប់អារម្មណ៍ថាជាអ្វីទេ ព្រោះពេល យប់។ ជនជាតិចិននោះបានមកស្នាក់នៅខុនដូរនេះរយៈពេលជិតមួយខែហើយ គាត់តែងតែចេញចូលក្នុងមួយយប់ពីរឬបី ដងម៉ោង១ឬម៉ោង២យប់ ពេលខ្លះចេញចូលម៉ោង៣ទៅ៤ជិតភ្លឺ។ ពេលគាត់ឈរចាំឡានមកទទួលយកគាត់មានសភាពភិតភ័យ ចុចទូរស័ព្ទ ខុសៗ ធ្វេភ្លាជានិច្ច។

- ក្រឡាបញ្ជីអានលទ្ធផលកោសល្យវិច័យគ្រឿងញៀនលេខ ៣២២៦៥/២១ ម.ព.អ.ជ.ប.គ.ញ ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២១ របស់មន្ទីរពិសោធន៍៖ សំណាកជាគ្រឿងញៀនប្រភេទក្រាមម្សៅថ្លា ឈ្មោះ **កេតាមីន**, ដែលមានកម្រិតភាពសុទ្ធ ៦៨.៩០% នៃទម្ងន់សរុប, វាស្ថិតក្នុងតារាងទី៣ មាត្រា៥ ចំណាត់ថ្នាក់គ្រឿងញៀនដូចមានចែងលម្អិតក្នុងតារាងឧបសម្ព័ន្ធច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនកម្ពុជា។

## <u>សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ</u>

គ្រឿងញៀនឆែកឆេររកឃើញនៅក្នុងរថយន្តដែលធ្វើដំណើរដោយពួកគាត់ទាំងពីរ តាមរយៈភស្តុតាងជាវីឌីអូ និងភស្តុតាងនៅក្នុងសំណុំរឿងចង្អុលបង្ហាញភាគច្រើនទៅលើជនជាប់ចោទឈ្មោះ [redacted] WEIJUN ជាម្ចាស់នៃគ្រឿងញៀននេះ។ ដូចនេះនៅក្នុងរឿងនេះ តំណាងអយ្យការសម្រេចតម្កល់ការចោទប្រកាន់ទៅជនជាប់ចោទឈ្មោះ [redacted] WEIJUN ពីបទ **រក្សាទុក, ដឹកជញ្ជូន និងជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** តាមបញ្ញត្តិមាត្រា ៤៨ កថាខណ្ឌទី១, ទី២, ទី៣ និងទី៦ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។ ចំពោះជនជាប់ចោទឈ្មោះ [redacted] XIAOFEI ស្នើតុលាការពិនិត្យ និងសម្រេចតាមច្បាប់។

## <u>សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ</u>

មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] XIAOFEI បានធ្វើការសន្និដ្ឋានថា កូនក្តីរបស់ខ្លួនមានអត្តចរិតសុភាពរាបសារ ស្លូតបូត ពេលដែលឃើញប៉ុស្តិ៍ត្រួតពិនិត្យបានបើករថយន្តចូលឱ្យសមត្ថកិច្ចធ្វើការត្រួតពិនិត្យធម្មតាមិនមានការគេចវេះនោះទេ ហើយនៅក្រោយពេលឆែកឆេរអាការៈរបស់គាត់មានសភាពធម្មតា មិនមានការភិតភ័យទេ ព្រមទាំងបានចូលរួមសហការណ៍ជាមួយសមត្ថកិច្ចទៀតផង។ ម្យ៉ាងទៀត ប្រសិនបើគាត់ដឹងថាមានគ្រឿងញៀននៅក្នុងរថយន្តរបស់គាត់មែននោះ គាត់មិនបើករថយន្តចល័តពីកន្លែងមួយទៅកន្លែងមួយទៀតដូច្នេះឡើយ។ ទាំងអស់នេះបញ្ជាក់ថាគ្រឿងញៀននេះមិនមែនជារបស់កូនក្តីខ្លួនឈ្មោះ [redacted] XIAOFEI ឡើយ ហើយក៏មិនបានប្រព្រឹត្តដូចការចោទប្រកាន់នោះ ៧



Scanned with CamScanner

ឡើយ។ ហេតុនេះ ស្នើសុំឱ្យតុលាការសម្រេចឱ្យកូនក្តីខ្លួនឈ្មោះ [redacted] XIAOFEI រួចផុតពីបទចោទប្រកាន់។

មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] WEIJUN បានធ្វើការសន្និដ្ឋានថា៖ គ្រឿងញៀនរកឃើញនៅក្នុងរថយន្តដែលធ្វើដំណើរដោយពួកគាត់ទាំងពីរ នៅមានភាពស្រពេចស្រពិលនៅឡើយ មិនទាន់អាចបញ្ជាក់ថាជារបស់ឈ្មោះ [redacted] XIAOFEI ឬ ជារបស់ឈ្មោះ [redacted] WEIJUN នោះទេ។ ហេតុនេះ ស្នើសុំឱ្យតុលាការសម្រេចធ្វើនីតិវិធីចាត់របៀប។

## សម្តីចុងក្រោយរបស់ជនជាប់ចោទ

-ជនជាប់ចោទឈ្មោះ [redacted] XIAOFEI សំណូមពរសុំតុលាការមេត្តាដោះលែងខ្លួនអោយមានសេរីភាពវិញ ព្រោះខ្លួនពុំបានប្រព្រឹត្តដូចការចោទប្រកាន់ទេ។

-ជនជាប់ចោទឈ្មោះ [redacted] WEIJUN មិនមានសំណូមពរអ្វីទេ។

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទទាំងពីរនាក់

-ក្រោយពីបានស្តាប់ចម្លើយសាក្សីជាមន្ត្រីនគរបាលយុត្តិធម៌

-ក្រោយពីបានស្តាប់អំណានចម្លើយរបស់សាក្សី

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

-ក្រោយពីបានស្តាប់សម្តីចុងក្រោយរបស់ជនជាប់ចោទ

-ក្រោយពីបានពិនិត្យឯកសារភស្តុតាងនានា

-ក្រោយពីបានពិចារណាជាក្រុមប្រឹក្សាត្រឹមត្រូវតាមច្បាប់ហើយ

## សំអាងហេតុ

១ តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] WEIJUN ដែលបានឆ្លើយនាពេលសវនាការ ក៏ដូចជាចម្លើយដែលធ្លាប់បានឆ្លើយនៅតំណាក់កាលអយ្យការនិងចៅក្រមស៊ើបសួរ មានចំណុចមួយចំនួនដែលតុលាការគប្បីធ្វើការកត់សម្គាល់ដូចខាងក្រោម៖

១.១ ត្រង់ចំណុចដែលជនជាប់ចោទរូបនេះបានឆ្លើយថា៖ នៅពេលដែលឈ្មោះ [redacted] XIAOFEI បានមកដល់ខ្លួនបានយកដុំដែកអាល់ទែវែងមួយទៅដាក់នៅឃ្លុបឡានខាងក្រោយរបស់ [redacted] XIAOFEI, ដុំដែកអាល់ទែវែងនោះមានចងភ្ជាប់នឹងស្រោមដៃ មិនមែនចងខ្មៅនោះទេ។

**ចម្លើយនេះគឺជាចម្លើយមិនពិតដែលតុលាការមិនអាចជឿជាក់បាននោះទេ** ពីព្រោះ តាមរយៈភស្តុតាងជា វីឌីអូសុវត្ថិភាព ពិនិត្យឃើញថា ឈ្មោះ [redacted] WEIJUN បានលីអាល់ទែវែងមួយ នឹងបានកាន់ដុំដែក១ទៀតហើយដុំដែកអាល់ទែវែងនោះគឺឃើញមានភ្ជាប់ទៅនឹងវត្ថុខ្មៅមួយ ដែលមិនមានរូបរាងដូចជាស្រោមដៃ ដូចការអះអាងរបស់ជនជាប់ចោទនោះទេ។ ម្យ៉ាងវិញទៀតតាមរយៈការឆ្លើយបំភ្លឺរបស់សាក្សី ជាមន្ត្រីនគរបាលយុត្តិ

ធម៏ដែលជាអ្នកបានចុះប្រតិបត្តិការនេះផ្ទាល់ហើយក៏ជាអ្នកឆែកឆេរឡានទាំងមូលនោះគឺរកពុំឃើញមានស្រោមដៃ មាននៅក្នុងឡាន ឬនៅឃ្លុបឡានខាងក្រោយ ដូចការអះអាងរបស់ជនជាប់ចោទរូបនេះ នោះទេ ។

១.២ ត្រង់ចំណុចដែលជនជាប់ចោទរូបនេះបានឆ្លើយថា៖ គ្រឿងញៀននោះគឺបានរកឃើញពីរកន្លែង គឺរកឃើញនៅកាបូបកៅអីក្រោយ និងរកឃើញនៅឃ្លុបខាងមុខដែលខ្លួនអង្គុយ។ តាមរយៈការឆ្លើយបំភ្លឺរបស់សាក្សីដែលជាមន្ត្រីនគរបាលយុត្តិធម៏ដែលជាអ្នកបានចុះប្រតិបត្តិការនេះបានបញ្ជាក់នាពេលសវនាការយ៉ាងច្បាស់ថាពេលឆែកឆេរនោះគឺឃើញតែមួយកន្លែងនោះទេ គឺបានរកឃើញថង់ខ្មៅមួយកញ្ចប់នៅខាងមុខឃ្លុបអង្គុយរបស់ឈ្មោះ [redacted]WEIJUN តែប៉ុណ្ណោះ។ ឃើញថាជនជាប់ចោទរូបនេះឆ្លើយមិនពិតនោះទេ។

១.៣ ត្រង់ចំណុចដែលជនជាប់ចោទរូបនេះបានឆ្លើយថា៖ នៅពេលសមត្ថកិច្ចឃាត់រថយន្តនោះ ខ្លួនមិនបានភិតភ័យអ្វីទាំងអស់។ ការឆ្លើយបែបនេះតុលាការមិនអាចជឿជាក់បាននោះទេ ពីព្រោះតាមរយៈការឆ្លើយបំភ្លឺរបស់សាក្សីដែលជាមន្ត្រីនគរបាលយុត្តិធម៏ ដែលជាអ្នកបានចុះប្រតិបត្តិការនេះនៅកើតហេតុនោះ បានបញ្ជាក់នាពេលសវនាការយ៉ាងច្បាស់ក្នុងន័យថា នៅពេលឃាត់រថយន្តហើយសមត្ថកិច្ចបានអោយជនជាប់ចោទចេញពីឡានដើម្បីធ្វើការត្រួតពិនិត្យឆែកឆេរពេលនោះ ឃើញថាជនជាប់ចោទឈ្មោះ[redacted]WEIJUN មានសភាពភិតភ័យញ័រខ្លួនពេលចុះពីរថយន្ត, ភិតភ័យស្លន់ស្លោ, ឆ្លើយក្រឡេចក្រឡុច ម្តងឆ្លើយបែបនេះ ម្តងឆ្លើយបែបនេះ ពេលសមត្ថកិច្ចសាកសួរ ហើយថែមទាំងមិន ព្រមសហការជាមួយសមត្ថកិច្ចនោះទេ។ លើសពីនេះទៀតតាមការបំភ្លឺរបស់ សាក្សីឈ្មោះ [redacted]វត្ថា ដែលជាសន្តិសុខការពារនៅកន្លែងដែលជនជាប់ចោទរូបនេះស្នាក់នៅ ហើយក៏ជាសន្តិសុខមួយរូបដែលបានឃើញសភាពរបស់[redacted]WEIJUN នាពេលយប់នោះគឺបានបញ្ជាក់ផងដែរថា ពេលគាត់ឈរចាំឡានមកទទួលយកគាត់មានសភាពភិតភ័យ ចុចទូរស័ព្ទខុសៗ ឆ្កេឆ្កាជានិច្ច។ ហេតុនេះតុលាការគប្បីពិចារណា អំពីបុគ្គលិកលក្ខណៈរបស់ជនជាប់ចោទរូបនេះថាតើហេតុអ្វីបានជាភ័យយ៉ាងខ្លាំងពេលសមត្ថកិច្ចឃាត់រថយន្ត។

១.៤ ត្រង់ចំណុចដែលជនជាប់ចោទរូបនេះបានឆ្លើយថា៖ដុំដែកមានតែមួយនោះទេ ហើយពេលលើកនោះក៏បានអោយសន្តិសុខជួយផងដែរ។ ចម្លើយនេះគឺជាចម្លើយមិនពិតដែលតុលាការមិនអាចជឿជាក់បាននោះទេពីព្រោះ សាក្សីឈ្មោះ [redacted] វត្ថា ដែលជាសន្តិសុខការពារនៅកន្លែងដែលជនជាប់ចោទរូបនេះស្នាក់នៅ បានបញ្ជាក់ថា “*នៅយប់កើតហេតុជនជាតិចិនលីដែកអាល់ទែរចំនួនពីរគឺធំមួយតូចមួយ។ ដែកអាល់ទែរធំ ពេលខ្លួនឃើញ គាត់លីអាល់ទែរខ្លួនទៅរកជួយលើកដាក់គូទឡាន តែគាត់ពុំឱ្យខ្លួនប៉ះនោះទេ ដោយគាត់បាននិយាយថាមិនបាច់ជួយទេ*” ។ តាមការពិនិត្យលើកាមេរ៉ាសុវត្ថិភាពតុលាការក៏បានឃើញ សន្តិសុខ ឈ្មោះ [redacted] វត្ថា បានព្យាយាមទៅជួយលើកផងដែរ ប៉ុន្តែជនជាប់ចោទ [redacted] WEIJUN មិនបានអោយជួយលើកនោះទេ ។ ហេតុនេះតុលាការគប្បីពិចារណាថាតើមូលហេតុអ្វីមិនអោយជួយតើមកពីខ្លាចសន្តិសុខឃើញថង់ខ្មៅ នោះឬយ៉ាងណា ?

២ តាមការបំភ្លឺរបស់អនុសេនីយ៍ឯក [redacted]ម៉ារ៉ា នាយផ្នែកប្រឆាំងគ្រឿងញៀន នៃអធិការដ្ឋាននគរបាលខណ្ឌចំការមន, លោក [redacted] រស្មី អធិការរងនៃអធិការដ្ឋាននគរបាលខណ្ឌចំការមន, លោក [redacted]ដ្ឋា ជានាយផ្នែកអន្តរាគម៍ដែលជាអ្នកចុះប្រតិបត្តិការផ្ទាល់នៅថ្ងៃកើតហេតុនោះ ឃើញថាសមត្ថកិច្ចទាំង៣រូបនេះបានបញ្ជាក់ដូចៗគ្នា អំពី

បុគ្គលិកលក្ខណៈរបស់ជនជាប់ចោទឈ្មោះ [redacted]WEIJUN នៅពេលនោះឃើញថាមានសភាព ញ័រញ៉ូវ ភិតភ័យ ស្លន់ស្លោរ មិនសហការជាមួយសមត្ថកិច្ច ឆ្លើយម្តងបែបនេះ ម្តងបែបនោះ ដោយឡែកចំពោះជនជាប់ចោទ [redacted] XIAOFEI វិញគឺមានសភាពធម្មតាប្រក្រតីហើយបានសហការជាមួយសមត្ថកិច្ចបានយ៉ាងល្អ មិនភិតភ័យ មិនស្លល់ស្លោ អាចបញ្ជាក់បានថាជនជាប់ចោទរូបនេះ ខ្លួនពុំបានធ្វើខុសអ្វីនោះទេ ។

តាមរយៈនេះក្រុមប្រឹក្សាអាចវាយតម្លៃបានថា ជនជាប់ចោទឈ្មោះ [redacted]WEIJUN តែងតែឆ្លើយនូវចម្លើយដែលមិនពិតជាច្រើនដើម្បីជាលេសក្នុងការទទួលខុសត្រូវ ហើយជនជាប់ចោទរូបនេះ មានការភិតភ័យពីព្រោះខ្លាចសមត្ថកិច្ច រែកឃើញគ្រឿងញៀនដែលខ្លួនបានដាក់ក្នុងឃ្លុបឡានខាងមុខដែលបានអង្គុយ ។

៣ ក្រោយពីបានឆែកឃើញថង់ខ្មៅជាគ្រឿងញៀននៅក្នុងឃ្លុបខាងមុខដែល ជនជាប់ចោទឈ្មោះ [redacted] WEIJUN អង្គុយនោះរួចមក សមត្ថកិច្ចក៏បានចុះទៅធ្វើការឆែកឆេរផ្ទះរបស់ជនជាប់ចោទឈ្មោះ [redacted]WEIJUN ហើយរកឃើញនូវសម្ភារៈប្រើប្រាស់គ្រឿងញៀនមួយចំនួនផងដែរ ។

៤ តាមការបញ្ជាក់របស់សាក្សីឈ្មោះ [redacted] វត្ថា ដែលជាសន្តិសុខការពារនៅកន្លែងស្នាក់នៅរបស់ជនជាប់ចោទឈ្មោះ [redacted]WEIJUN ដែលពេលនោះគាត់គឺជាបុគ្គលម្នាក់ដែលបានឃើញ និងបានព្យាយាមជួយលើកដុំដែករបស់ជនជាប់ចោទឈ្មោះ[redacted]WEIJUN អាចបញ្ជាក់ថាមាន**វត្ថុពណ៌ខ្មៅថង់ភ្ជាប់នៅនឹងដុំដែកអាល់ទែ** តែខ្លួនមិនបានចាប់អារម្មណ៍ថាជាអ្វីនោះទេព្រោះពេលយប់។

សមត្ថកិច្ចឈ្មោះ [redacted] **រស្មី** បានបញ្ជាក់ថានៅក្នុងវីឌីអូនោះសមត្ថកិច្ចសម្គាល់ឃើញមានកញ្ចប់ថង់មួយជាប់ពីក្រោយដុំដែកអាល់ទែរបស់ឈ្មោះ [redacted]WEIJUN ។

តុលាការបានធ្វើការពិនិត្យលើភស្តុតាងជា កាមេរ៉ាវីឌីអូ សុវត្ថិភាព (CCTV) នោះ ឃើញថាពិតជាមានរូបជនជាប់ចោទឈ្មោះ [redacted]WEIJUN បានដើរចេញពីខាងក្នុងអាគារមកខាងក្រៅដោយមានកាន់ដុំដែកចំនួន២ គឺដុំដែកអាល់ទែធំវែងមួយ និងដុំដែកតូចខ្លីមួយ ហើយនៅដុំដែកអាល់ទែធំវែង នោះគឺឃើញមានរូបរាងដូចជាថង់ពណ៌ខ្មៅមួយដែលចងភ្ជាប់ទៅនឹងដុំដែកអាលទែនោះ។ ឃើញថាមានភាពស៊ីសង្វាក់ស្របទៅនឹងការបំភ្លឺរបស់ មន្ត្រីនគរបាលយុត្តិធម៌ឈ្មោះ **យស់ ម៉ារ៉ា** ដែលបានបញ្ជាក់ថា “**កញ្ចប់ថ្នាំសង្ស័យជាថ្នាំញៀនគឺដកហូតចេញពីក្នុងរថយន្ត ដកចេញពីក្នុងកេះខាងស្តាំរបស់រថយន្តដែលនៅទល់មុខកន្លែងឈ្មោះ [redacted]WEIJUN អង្គុយ ហើយវាមាន**ទំហំ និងរូបរាងប្រហាក់ប្រហែលទៅនឹងកញ្ចប់ដែលជាប់ទៅនឹងដុំដែកលើកអាល់ទែរបស់ឈ្មោះ[redacted]WEIJUN **ដូចមាននៅក្នុងវីឌីអូនោះ** ។ ”

ដូច្នេះសរុបរួមមក ផ្អែកតាមការបំភ្លឺរបស់ សមត្ថកិច្ចជាមន្ត្រីនគរបាលយុត្តិធម៌ ដែលជាអ្នកចុះប្រតិបត្តិការនេះផ្ទាល់, តាមចម្លើយរបស់សាក្សីឈ្មោះ [redacted]វត្ថា ដែលជាសន្តិសុខការពារនៅអាគារស្នាក់នៅរបស់ជនជាប់ចោទឈ្មោះ[redacted]WEIJUN ហើយក៏ជាអ្នកបានឃើញជនជាប់ចោទរូបនេះលីអាលទែរមាន**វត្ថុពណ៌ខ្មៅថង់ភ្ជាប់នៅនឹងដុំដែកអាល់ទែនោះ** ក៏ដូចជាតាមរយៈកាមេរ៉ាសុវត្ថិភាពដែលតុលាការបានពិនិត្យនោះ ទាំងអស់នេះអាចអោយ ៧/

តុលាការវាយតម្លៃបានថា វត្ថុខ្មៅដែលនៅចងភ្ជាប់ដុំដែកអាល់ទែរវែងរបស់ជនជាប់ចោទឈ្មោះ [redacted] WEIJUN នោះគឺជាកញ្ចប់ថង់ខ្មៅដែលមានផ្ទុកគ្រឿងញៀនពិតប្រាកដមែន ពីព្រោះក្រោយពីសមត្ថកិច្ចបានធ្វើការឆែកឆេររថយន្តទាំងមូលនោះគឺពិតជាបានឃើញថង់ខ្មៅនោះដែលនៅក្នុងឃ្លុបខាងមុខរបស់ [redacted] WEIJUN ពិតមែនក្រៅពីនោះគឺពុំឃើញមានអ្វីនោះទេ ដែលមិនដូចការអះអាងរបស់ [redacted] WEIJUN ថាជាស្រោមដៃនោះទេ ពោលគឺសមត្ថកិច្ចរកឃើញតែថង់ខ្មៅនោះ ហើយរកពុំឃើញស្រោមដៃអ្វីនោះឡើយ។ ហេតុនេះតុលាការជឿជាក់បានថាថង់ខ្មៅមានផ្ទុកសារធាតុញៀននោះគឺជារបស់ [redacted] WEIJUN ដែលបានយកលាក់ទុកក្នុងឃ្លុបឡានខាងមុខដែលខ្លួនអង្គុយពិតប្រាកដមែន ស្របតាមការអះអាងរបស់ឈ្មោះ [redacted] XIAOFEI ដែលបាននិយាយថា [redacted] WEIJUN បានស្រវេស្រវាយកអីវ៉ាន់ដាក់ឃ្លុបឡានខាងមុខគាត់អង្គុយ ។

ដូច្នេះ តុលាការយល់ឃើញថាមានភស្តុតាងដាក់បន្ទុក លើឈ្មោះ [redacted] WEIJUN ពីបទ៖ **រក្សាទុក, ដឹកជញ្ជូន និងជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចគល់ស្ពានហង្ស ផ្លូវបេតុង ក្រុមទី៧៨ ភូមិ១៤ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី២០ ខែមករា ឆ្នាំ២០២១ តាមបញ្ញត្តិមាត្រា ៤៨ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

៥ តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] XIAOFEI ដែលបានឆ្លើយនៅដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌, ដំណាក់កាលអយ្យការ, ដំណាក់កាលចៅក្រមស៊ើបសួរ, ក៏ដូចជានាពេលសវនាការ ឃើញថា៖ ជនជាប់ចោទរូបនេះបានឆ្លើយបដិសេធនៅគ្រប់ដំណាក់កាលនៃនីតិវិធីថាខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់នោះទេ។ តាមចម្លើយរបស់ជនជាប់ចោទរូបនេះដែលបានឆ្លើយកន្លងមក មានចំណុចមួយចំនួនដែលតុលាការគប្បីធ្វើការកត់សម្គាល់ដូចខាងក្រោម៖

៥.១ ត្រង់ចំណុចដែលជនជាប់ចោទបានឆ្លើយថា៖ ពេលខ្លួនទៅយក [redacted] WEIJUN ហើយខ្លួនក៏បានជូនមកកោះពេជ្រ ពេលនោះមានសមត្ថកិច្ចឃាត់ឆែករថយន្ត។ ពេលនោះ [redacted] WEIJUN ស្រាប់តែមានសភាពស្លន់ស្លោ ហើយខ្លួនក៏ឆ្ងល់ហើយសួរគាត់ថា "*មានរឿងអ្វី? កើតអីបានជាភ័យ ខ្ញុំមានបណ្ណ័បើកបរត្រឹមត្រូវមិនអីទេ ហើយក៏មិនបានផឹកស្រវឹងដែរ* " ។ ពេលនោះឈ្មោះ [redacted] WEIJUN មិនបានឆ្លើយតបមកខ្លួនវិញទេ គិតតែនិយាយថា "*ដាច់ហើយៗ*" និងបានស្រវេស្រវារកយកឥវ៉ាន់របស់គាត់មកទុកនៅឃ្លុបឡានខាងមុខដែលគាត់អង្គុយ ចំណែកខ្លួនវិញមិនបានភិតភ័យអ្វីនោះទេ ព្រោះមិនដឹងថាត្រូវភ័យរឿងអីនោះទេ។ តាមរយៈចម្លើយនេះឃើញថាមានភាពស៊ើសង្វាក់ទៅនឹងការបំភ្លឺរបស់សមត្ថកិច្ចដែលបានបញ្ជាក់ថាចំពោះ [redacted] XIAOFEI ពេលឃាត់ អោយចុះពីរថយន្តនោះគឺមិនមានភាពភិតភ័យអ្វីនោះទេគឺបានសហការបានល្អជាមួយសមត្ថកិច្ច។ ហេតុនេះតុលាការអាចជឿជាក់បានចំពោះចម្លើយនេះ ។

៦ ចំពោះជនជាប់ចោទឈ្មោះ [redacted] XIAOFEI ក្រោយពីបានធ្វើការដេញដោល និងស្តាប់ការបំភ្លឺរបស់សាក្សី ក៏ដូចជាពិនិត្យលើឯកសារភស្តុតាងនានា ឃើញថា មិនមានសញ្ញាណណាមួយ ឬភស្តុតាងដាក់បន្ទុកណាមួយច្បាស់លាស់ដែលអាចអោយតុលាការកំណត់បានថាជនជាប់ចោទរូបនេះបានដឹងលឺនិងពាក់ពន្ធទៅនឹងកញ្ចប់ថង់ខ្មៅ ៗ/

ថ្នាំញៀននេះទេ ។ រួមទាំងបុគ្គលិកលក្ខណៈរបស់ជនជាប់ចោទឃើញថាបានសហការល្អជាមួយសមត្ថកិច្ច។ តាមកំណត់ហេតុឆែកឆេរផ្ទះរបស់ [redacted] XIAOFEI បានបញ្ជាក់ផងដែរថារកមិនឃើញមានវត្ថុតាងឬសម្ភារៈអ្វីពាក់ព័ន្ធជាមួយបទល្មើសគ្រឿងញៀននោះទេ។ ដូច្នេះឃើញថានៅមានវមតិសង្ស័យ ដែលតុលាការមិនទាន់អាចកំណត់បានថាជនជាប់ ចោទរូបនេះបានប្រព្រឹត្តអំពើដូចការចោទប្រកាន់នោះទេ ។ យល់ឃើញថាពុំទាន់មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] XIAOFEI ដោយនៅមានវមតិសង្ស័យដែលត្រូវបានជាអត្ថប្រយោជន៍ដល់ជនជាប់ចោទរូបនេះ ស្របតាមមាត្រា៣៥១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ និងមាត្រា៣៨ នៃច្បាប់រដ្ឋធម្មនុញ្ញ។

យល់ឃើញថាមិនមានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] XIAOFEI ពីបទ៖ **រក្សាទុក, ដឹកជញ្ជូន និងជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចគល់ស្ពានហង្ស ផ្លូវបេតុង ក្រុមទី៧៨ ភូមិ១៤ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី២០ ខែមករា ឆ្នាំ២០២១ តាមបញ្ញត្តិមាត្រា ៤៨ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។ហេតុនេះតុលាការគប្បីអោយជនជាប់ចោទត្រូវបានរួចខ្លួនពីបទចោទ ស្របតាមមាត្រា៣៥០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

៧ តាមលទ្ធផលកោសល្យវិច័យគ្រឿងញៀនរបស់មន្ទីរពិសោធន៍ នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន លេខ ៣២២៦៥/២១ ម.ព.អ.ជ.ប.គ.ញ ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២១ របស់មន្ទីរពិសោធន៍៖ សំណាកជាគ្រឿងញៀនប្រភេទក្រាមម្សៅថ្លា ឈ្មោះ **កេតាមីន**, ដែលមានកម្រិតភាពសុទ្ធ ៦៨.៩០% នៃទម្ងន់សរុប, រាស្ថិតក្នុងតារាងទី៣ មាត្រា៥ ចំណាត់ថ្នាក់គ្រឿងញៀនដូចមានចែងលម្អិតក្នុងតារាងឧបសម្ព័ន្ធច្បាប់ស្តីពីការត្រួត ពិនិត្យគ្រឿងញៀនកម្ពុជា។ តាមកំណត់ហេតុទទួលវត្ថុចាប់យកលេខ: ៩៤៣ រ.វ.ត របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០២១ ឃើញថាវត្ថុតាងដែលចាប់យកបាននោះមានទម្ងន់ ៥៩០.៥៩ ក្រាម ដូច្នេះតាមការគណនារកបរិមាណភាពសុទ្ធលើវត្ថុចាប់យកពីជនជាប់ចោទមានកម្រិតសារធាតុញៀនសុទ្ធទម្ងន់ $\frac{\text{៥៩០.៥៩ ក្រាម } x \text{ ៦៨.៩០\%}}{\text{១០០}}$ = ៤០៦.៩១៦៥១ ក្រាម។

៨ តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ សន្និដ្ឋានថា គ្រឿងញៀនឆែកឆេររកឃើញនៅក្នុងរថយន្តដែលធ្វើដំណើរដោយពួកគាត់ទាំងពីរ តាមរយៈភស្តុតាងជាវីដេអូ និងភស្តុតាងនៅក្នុងសំណុំរឿងចង្អុលបង្ហាញភាគច្រើនទៅលើជនជាប់ចោទឈ្មោះ [redacted] WEIJUN ជាម្ចាស់នៃគ្រឿងញៀននេះ។ ដូចនេះនៅក្នុងរឿងនេះ តំណាងអយ្យការសម្រេចតម្កល់ការចោទប្រកាន់ទៅជនជាប់ចោទឈ្មោះ [redacted] WEIJUN ពីបទ **រក្សាទុក, ដឹកជញ្ជូន និងជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** តាមបញ្ញត្តិមាត្រា ៤៨ កថាខណ្ឌទី១, ទី២, ទី៣ និងទី៦ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។ ចំពោះជនជាប់ចោទឈ្មោះ [redacted] XIAOFEI ស្នើតុលាការពិនិត្យ និងសម្រេចតាមច្បាប់។ តុលាការគប្បីពិចារណាសម្រេចតាមអង្គហេតុនឹងអង្គច្បាប់ ។

៩ មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] WEIJUN បានធ្វើការសន្និដ្ឋានថាស្នើសុំអោយតុលាការចាត់របៀបព្រោះនៅមិនទាន់ច្បាស់ថាជាគ្រឿងញៀនរបស់អ្នកណា។ ផ្អែកតាមសំអាងហេតុខាងលើតុលាការយល់

ឃើញថាមានមូលដ្ឋានគ្រប់គ្រាន់ហើយដើម្បីកំណត់ថាគ្រឿងញៀននោះគឺជារបស់អ្នកណា ហេតុនេះ គប្បីតុលាការពិនិត្យនិងសម្រេចតាមច្បាប់ ។

១០ ការប្រព្រឹត្តអំពើល្មើសរបស់ជនជាប់ចោទឈ្មោះ [redacted] WEIJUN ធ្វើឡើងដោយមានចេតនា និងមានស្មារតីទទួលខុសត្រូវគ្រប់គ្រាន់ និងជាអំពើដែលធ្វើឱ្យសង្គមជាតិកើនឡើងនូវបទល្មើសដែលបង្កឡើងដោយគ្រឿងញៀន និងជាអំពើដែលធ្វើឱ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ ហើយបំពានទៅលើនីត្យានុកូលភាព សង្គមដែលច្បាប់បានការពារយ៉ាងម៉ឺងម៉ាត់បំផុត ។

១១ មានភស្តុតាងដាក់បន្ទុក និងពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ [redacted] WEIJUN ពីបទ៖ **រក្សាទុក, ដឹកជញ្ជូន និងជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចគល់ស្ពានហង្ស ផ្លូវបេតុង ក្រុមទី៧៨ ភូមិ១៤ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី២០ ខែមករា ឆ្នាំ២០២១ តាមបញ្ញត្តិមាត្រា ៤៨ កថាខណ្ឌទី១, ទី២, ទី៣ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

១២ ពុំមានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើឈ្មោះ [redacted] XIAOFEI ពីបទ៖ **រក្សាទុក, ដឹកជញ្ជូន និងជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចគល់ស្ពានហង្ស ផ្លូវបេតុង ក្រុមទី៧៨ ភូមិ១៤ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី២០ ខែមករា ឆ្នាំ២០២១ តាមបញ្ញត្តិមាត្រា ៤៨ កថាខណ្ឌទី១, ទី២, ទី៣ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

១៣ វត្ថុចាប់យករួមមាន៖

- ក្រាមពណ៌សថ្លាជាគ្រឿងញៀនប្រភេទកេតាមីនទម្ងន់ ៥៩០.៥៩ ក្រាម ។
- ដុំដែក ចំនួន ០១ ដុំ
- ទូរស័ព្ទដៃម៉ាក IPHONE ពណ៌ស (បកសំបកខាងក្រោយ និងបែកអេក្រង់) ចំនួន០១គ្រឿង។ (មិនដំណើរការ)
- កាបូបលុយចំនួន០១ ។
- កាតពណ៌ក្រហម លេខ 2558508 ចំនួន០១ ។
- កាត ABA លេខ 4286 0901 56770511 ចំនួន០១ ។
- កាត WING លេខ 5018 1880 0201 3152 ចំនួន០១។

គប្បីតុលាការពិចារណា និងសម្រេចតាមច្បាប់។

## <u>ហេតុដូច្នេះសម្រេច</u>

១/-ឱ្យឈ្មោះ [redacted] XIAOFEI ភេទប្រុស កើតថ្ងៃទី១១ ខែមករា ឆ្នាំ១៩៧១ ជនជាតិចិន (ដែលមានសាវតាជាតិដូចខាងលើ) រួចខ្លួនពីបទចោទ ពីបទ៖ **រក្សាទុក, ដឹកជញ្ជូន និងជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចគល់ស្ពានហង្ស ផ្លូវបេតុង ក្រុមទី៧៨ ភូមិ១៤ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី២០ ខែមករា ឆ្នាំ២០២១ តាមបញ្ញត្តិមាត្រា ៤៨ កថាខណ្ឌទី១, ទី២, ទី៣ និងទី៦ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

២/-ផ្តន្ទាទោសឈ្មោះ [redacted] WEIJUN ភេទប្រុស កើតថ្ងៃទី០៦ ខែមេសា ឆ្នាំ១៩៨៥ ជនជាតិចិន (ដែលមានសាវតាជាតិដូចខាងលើ) ដាក់ពន្ធនាគារកំណត់ ១៣(ដប់បី) ឆ្នាំ និងពិន័យចំនួន ៣០,០០០,០០០ (**សាមសិបលាន**) **រៀល** ។/



Scanned with CamScanner

ពិបទ៖ រក្សាទុក, ដឹកជញ្ជូន និងជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចគល់ស្ពានហង្ស ផ្លូវបេតុង ក្រុមទី៧៨ ភូមិ១៤ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី២០ ខែមករា ឆ្នាំ២០២១ តាមបញ្ញត្តិមាត្រា ៤៨ កថាខណ្ឌទី១, ទី២, ទី៣ និងទី៦ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

៣/-វត្ថុចាប់យកត្រូវរឹបអូសរួមមាន៖

- ក្រាមពណ៌សថ្លាជាគ្រឿងញៀនប្រភេទកេតាមីន ទម្ងន់ ៥៩០.៥៩ (ប្រាំរយកៅសិបក្បៀសហាសិបប្រាំបួន) ក្រាម ។
- ដុំដែកចំនួន ០១ ដុំ ។
- ទូរស័ព្ទដៃម៉ាក IPHONE ពណ៌ស (បកសំបកខាងក្រោយ និងបែកអេក្រង់) ចំនួន០១គ្រឿង។ (មិនដំណើរការ) ។
- កាបូបលុយចំនួន០១ ។
- កាតពណ៌ក្រហម លេខ 2558508 ចំនួន០១ ។
- កាត ABA លេខ 4286 0901 56770511 ចំនួន០១ ។
- កាត WING លេខ 5018 1880 0201 3152 ចំនួន០១ ។

ដែលមានក្នុងកំណត់ហេតុទទួលវត្ថុចាប់យកលេខ ២៣៤ រ.វ.ត ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០២១ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

៤/-វត្ថុចាប់យកត្រូវប្រគល់ឱ្យម្ចាស់ដើម ឈ្មោះ [redacted] XIAOFEI វិញមាន ៖

- ទូរស័ព្ទដៃម៉ាក IPHONE ទឹកមាស ចំនួន០១គ្រឿង (មិនដំណើរការ) ។
- ទូរស័ព្ទដៃម៉ាក ហ៊ូវ៉ៃ ពណ៌ខ្មៅ (បែកសំបកខាងក្រោយ) ចំនួន០១គ្រឿង (មិនដំណើរការ) ។

សាលក្រមនេះ ប្រកាសជាសាធារណៈ នៅថ្ងៃទី១២ ខែមករា ឆ្នាំ២០២២ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] XIAOFEI និងជនជាប់ចោទឈ្មោះ [redacted] WEIJUN ។ រក្សាសិទ្ធិប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។៚

| ក្រឡាបញ្ជីសវនាការ | ចៅក្រមប្រឹក្សា | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|---|
| ហត្ថលេខានិងត្រា | ហត្ថលេខា | ហត្ថលេខា | ហត្ថលេខានិងត្រា |

[redacted]

---

បានឃើញ
ប្រធានក្រុមប្រឹក្សា

[redacted]

"បានចម្លងត្រឹមត្រូវតាមច្បាប់ដើម"
ថ្ងៃពុធ ១០កើត ខែបុស្ស ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ, ថ្ងៃទី១២ ខែមករា ឆ្នាំ២០២២
ក្រឡាបញ្ជី

[redacted]